ធនាគារកម្ពុជាសាធារណៈ
CAMBODIAN PUBLIC BANK 柬埔寨大眾銀行

## ខ និងលក្ខខណ្ឌគណនីប្រាក់បញ្ញើមានកាលកំណត់អនឡាញ

### ១. សិទ្ធិបើកគណនី

១.១ គណនីប្រាក់បញ្ញើមានកាលកំណត់អនឡាញ (ហៅកាត់ថា "eFD") គឺជាគណនីប្រាក់បញ្ញើមានកាលកំណត់ដែលអនុញ្ញាតឱ្យបង្កើតគណនី ដាក់ប្រាក់បញ្ញើ និងដកប្រាក់ ហើយប្រតិបត្តិការគណនីនេះត្រូវធ្វើឡើងតាមប្រព័ន្ធអនឡាញ តាមរយៈកម្មវិធីប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ីនធើណិត/ប្រព័ន្ធធនាគារចល័ត (ហៅកាត់ថា "កម្មវិធីប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ីនធើណិត/ប្រព័ន្ធធនាគារចល័ត")។

១.២ eFD គឺជាផលិតផលប្រាក់បញ្ញើមានកាលកំណត់ដែលមានភាពងាយស្រួល។

១.៣ eFD អាចបើកបានតែអតិថិជនឯកត្តបុគ្គលដែលមានអាយុ ១៨ ឆ្នាំឡើងទៅ និងមានគណនីចរន្ត ឬគណនីសន្សំបុគ្គល (គណនីចរន្តសន្សំ) ព្រមទាំងបានចុះឈ្មោះប្រើប្រាស់កម្មវិធីប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ីនធើណិត/ប្រព័ន្ធធនាគារចល័ត (ហៅថា "ម្ចាស់គណនី")។

១.៤ គណនី eFD មិនអាចបើក ឬធ្វើប្រតិបត្តិការបាន ក្នុងករណីប្រតិបត្តិការគណនីតម្រូវឱ្យ "**ចុះហត្ថលេខាដោយម្ចាស់គណនីទាំងពីរ**"។ គណនី eFD អាចបើកសម្រាប់គណនីចរន្តសន្សំរួម ដោយមធ្យោបាយធ្វើប្រតិបត្តិការគណនីតម្រូវឱ្យ "ចុះហត្ថលេខាដោយម្ចាស់គណនីតែម្នាក់ក្នុងចំណោមម្ចាស់គណនីទាំងពីរ" ។

១.៥ មិនមែនឯកត្តបុគ្គល គឺក្រុមហ៊ុនឯកកម្មសិទ្ធិ ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុន សមាគម ក្លឹប និងសង្គមមិនមានសិទ្ធិបើក ឬធ្វើប្រតិបត្តិការគណនី eFD ទេ។

### ២. ការបើកគណនី និងការដាក់ប្រាក់

២.១ គណនី eFD អាចបើក និងធ្វើប្រតិបត្តិការបានតែតាមអនឡាញតាមរយៈកម្មវិធីប្រតិបត្តិការតាមអ៊ីនធើណិត/ប្រព័ន្ធធនាគារចល័តប៉ុណ្ណោះ។

២.២ ប្រតិបត្តិការនៅតាមបញ្ជរ**មិន**ត្រូវបានអនុញ្ញាតឡើយ។

២.៣ គណនីចរន្តសន្សំផ្ទាល់ខ្លួនត្រូវតែជ្រើសរើស អំឡុងពេលបើកគណនីប្រាក់បញ្ញើមានកាលកំណត់ eFD (ហៅកាត់ថា "គណនីចរន្តសន្សំ") និងកំណត់ជាគណនីប្រាក់បញ្ញើមានកាលកំណត់ eFD សម្រាប់ការដាក់ប្រាក់/ដកប្រាក់/ផ្ទេរការប្រាក់ចូលគណនី។

២.៤ គណនី eFD នឹងត្រូវបានភ្ជាប់ទៅគណនីចរន្តសន្សំ។

២.៥ ព័ត៌មានអតិថិជន eFD ត្រូវដូចគ្នាទៅនឹងព័ត៌មានគណនីចរន្តសន្សំ។

២.៦ ការដាក់ប្រាក់បញ្ញើមានកាលកំណត់ eFD ច្រើនដងត្រូវបានអនុញ្ញាត ហើយប្រតិបត្តិការអាចធ្វើបានពេញ ២៤ ម៉ោង ក្នុងមួយសប្តាហ៍។

២.៧ រាល់ការដាក់ប្រាក់បញ្ញើមានកាលកំណត់ eFD ត្រូវធ្វើឡើងក្នុងរយៈពេលចន្លោះពីមួយ (១) ខែ ទៅដប់ (១២) ខែ ហើយអត្រាការប្រាក់ត្រូវកំណត់ដោយធនាគារគ្រប់ពេល។

២.៨ ទឹកប្រាក់អប្បបរមាក្នុងគណនី eFD មានដូចខាងក្រោម៖

| អត្រាការប្រាក់ (ក្នុងមួយឆ្នាំ) | ប្រាក់បញ្ញើអប្បបរមាដំបូង | |
|---|---|---|
| រយៈពេល | ដុល្លារអាមេរិក | ខ្មែររៀល |
| ១ ខែ | ១.០០០ ដុល្លារអាមេរិក | ៤.០០០.០០០ រៀល |
| ២ ខែ | ១.០០០ ដុល្លារអាមេរិក | ៤.០០០.០០០ រៀល |
| ៣ ខែ | ៥០០ ដុល្លារអាមេរិក | ២.០០០.០០០ រៀល |
| ៦ ខែ | ៥០០ ដុល្លារអាមេរិក | ២.០០០.០០០ រៀល |
| ៩ ខែ | ៥០០ ដុល្លារអាមេរិក | ២.០០០.០០០ រៀល |
| ១២ ខែ | ៥០០ ដុល្លារអាមេរិក | ២.០០០.០០០ រៀល |

២.៩ មិនមានការចេញវិក្កយបត្រប្រាក់បញ្ញើមានកាលកំណត់ ជាទម្រង់រឹងសម្រាប់ការដាក់ប្រាក់បញ្ញើទេ។ ក្នុងករណីមិនមានវិក្កយបត្រប្រាក់បញ្ញើមានកាលកំណត់ជាទម្រង់រឹង ការដាក់បញ្ញើដែលឆ្លុះបញ្ចាំងតាមអនឡាញនឹងត្រូវភ្ជាប់លើម្ចាស់គណនី និងធនាគារ។

២.១០ បន្ទាប់ពីការដាក់បញ្ញើជោគជ័យ ការដាក់ប្រាក់បញ្ញើ/ប័ណ្ណបន្តដាក់ប្រាក់បញ្ញើ eFD នឹងត្រូវបានបង្កើត ដែលនឹងមានព័ត៌មានលម្អិតអំពីការដាក់ប្រាក់បញ្ញើនេះ។ ប្រតិបត្តិការនៅក្នុងគណនី eFD ក៏នឹងត្រូវបានបង្ហាញក្នុងរបាយការណ៍ប្រចាំត្រីមាសរបស់គណនី eFD ផងដែរ ដែលម្ចាស់គណនីអាចចូលមើលតាមរយៈកម្មវិធីប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ិនធើណិត/ប្រព័ន្ធធនាគារចល័ត។

២.១១ ប្រភពទឹកប្រាក់សម្រាប់ការដាក់ប្រាក់បញ្ញើ eFD នឹងត្រូវកាត់ចេញពីគណនីចរន្តសន្សំ។

២.១២ គណនីចរន្តសន្សំមិនអនុញ្ញាតឱ្យបិទទេ លុះត្រាតែប្រាក់បញ្ញើមានកាលកំណត់ eFD ដែលនៅសល់ត្រូវបានដក ហើយប្រាក់ដែលបានដកនឹងត្រូវបញ្ចូលទៅក្នុងគណនីចរន្តសន្សំ។

២.១៣ កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការដាក់បញ្ញើ eFD គឺជាថ្ងៃតែមួយនៃការដាក់ប្រាក់បញ្ញើ ប្រសិនបើបានដាក់ប្រាក់បញ្ញើដោយជោគជ័យ តាមរយៈកម្មវិធីប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ិនធើណិត/ប្រព័ន្ធធនាគារចល័ត។

២.១៤ រាល់ការដាក់បញ្ញើទាំងអស់ក្នុងគណនី eFD មិនត្រូវប្រើប្រាស់ជាទ្រព្យបញ្ចាំទេ។

## ៣. អត្រាការប្រាក់ និងការទូទាត់ការប្រាក់

៣.១ ការប្រាក់ទៅលើគណនីបញ្ញើមានកាលកំណត់ eFD នឹងត្រូវបានបញ្ចប់នៅពេលដល់កាលបរិច្ឆេទទូទាត់។ ការប្រាក់បង្គរទៅលើគណនីបញ្ញើមានកាលកំណត់ eFD គឺស្របតាមសិទ្ធិរបស់ធនាគារក្នុង

ការកាត់ទុកតាមតម្រូវការ ដូចជាពន្ធកាត់ទុក ឬពន្ធផ្សេងៗ ដែលបានកំណត់ ឬដាក់កំហិតពីពេលមួយទៅពេលមួយ។

៣.២ រយៈពេល និងវិធីសាស្ត្រទូទាត់ការប្រាក់មានដូចខាងក្រោម៖

| រយៈពេល | ការទូទាត់ការប្រាក់ |
|---|---|
| ១-១២ ខែ | • ផ្ទេរចូលគណនីចរន្តសន្សំ នៅពេលដល់កាលកំណត់ ឬ<br>• បន្ថែមលើប្រាក់ដើមនៅពេលដល់កាលកំណត់ |

៣.៣ វិធីសាស្ត្រទូទាត់ការប្រាក់នឹងត្រូវបានជ្រើសរើសបន្ទាប់ពីការដាក់បញ្ញើមានកាលកំណត់ eFD។

៣.៤ ការប្រាក់ត្រូវបានគណនាតាមចំនួនថ្ងៃជាក់ស្តែង។

## ៤. ការដកប្រាក់

៤.១ ការដកប្រាក់ពីគណនីប្រាក់បញ្ញើមានកាលកំណត់ eFD អាចធ្វើបានតែតាមរយៈកម្មវិធីប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ីនធើណិត/ប្រព័ន្ធធនាគារចល័ត ហើយការដកប្រាក់ចំនួនណាមួយពីគណនី eFD មិនអនុញ្ញាតឡើយ។

៤.២ បន្ទាប់ពីការដកប្រាក់ពីគណនីបញ្ញើមានកាលកំណត់ eFD ចំនួនប្រាក់ដើម និងការប្រាក់ដែលបានទទួល (ប្រសិនបើមាន) ត្រូវផ្ទេរដោយស្វ័យប្រវត្តិទៅគណនីចរន្តសន្សំ។

៤.៣ គណនីប្រាក់បញ្ញើមានកាលកំណត់ eFD មិនត្រូវបានអនុញ្ញាតឱ្យដកប្រាក់នៅថ្ងៃដាក់ប្រាក់ឡើយ។

## ៥. ការដកប្រាក់មុនកាលកំណត់

៥.១ ការដកប្រាក់មុនកាលកំណត់ពីគណនីប្រាក់បញ្ញើមានកាលកំណត់ eFD អាចធ្វើបានតែមួយថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដាក់បញ្ញើតាមរយៈកម្មវិធីប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ីនធើណិត/ប្រព័ន្ធធនាគារចល័ត។

៥.២ ចំពោះគណនីប្រាក់បញ្ញើមានកាលកំណត់ eFD ដែលមានរយៈពេល ១, ២ ឬ ៣ ខែ ត្រូវអនុវត្តដូចខាងក្រោម៖

ក. មិនមានការប្រាក់សម្រាប់ការដកប្រាក់មុនកាលកំណត់។

៥.៣ ចំពោះគណនីប្រាក់បញ្ញើមានកាលកំណត់ eFD ដែលមានរយៈពេលលើសពី ៣ ខែ គឺ ៩០ ថ្ងៃ ត្រូវអនុវត្តដូចខាងក្រោម៖

ក. ការប្រាក់មិនត្រូវបានទូទាត់សម្រាប់គណនីប្រាក់បញ្ញើមានកាលកំណត់ eFDs ដែលប្រមូលមុន រយៈពេល ៣ ខែ។ សម្រាប់គណនីប្រាក់បញ្ញើមានកាលកំណត់ eFDs ដែលប្រមូលមុនកាលកំណត់ គឺបន្ទាប់ពីការបញ្ចប់រយៈពេល ៣ ខែ គឺ ៩០ ថ្ងៃ ការប្រាក់នឹងត្រូវបានគណនា និងទូទាត់ពាក់កណ្តាល (១/២) នៃអត្រាកាប្រាក់ជាប់កិច្ចសន្យាដើមសម្រាប់ខែនីមួយៗដែលបានបញ្ចប់។

## ៦. ការបន្ត/បង្វិលបន្ត

៦.១ បន្ទាប់ពីដល់កាលបរិច្ឆេទផុតកំណត់ គណនី eFD នឹងត្រូវបន្តដោយស្វ័យប្រវត្តិសម្រាប់រយៈពេលដូចគ្នាតាមអត្រាការប្រាក់មានប្រសិទ្ធភាព។

## ៧. ការទទួលខុសត្រូវ

៧.១ ម្ចាស់គណនីយល់ព្រមឱ្យធនាគារផ្តល់ព័ត៌មានដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ស្របតាមសារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជា និង/ឬក្រុមហ៊ុននៅក្នុងសម្ព័ន្ធធនាគារសាធារណៈ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងសម្រាប់ធ្វើការវាយតម្លៃឥណទាន។

៧.២ ក្នុងករណីធនាគារប្រើសេវាមេធាវី ឬតម្រូវឱ្យជួលមេធាវី ដើម្បីអនុវត្តសិទ្ធិណាមួយរបស់ខ្លួននៅក្នុងខ និងលក្ខខណ្ឌនេះ ឬតាមនីតិវិធីតុលាការ ឬលក្ខណៈណាមួយពាក់ព័ន្ធនឹងគណនីប្រាក់បញ្ញើមានកាលកំណត់ eFD ម្ចាស់គណនីត្រូវទទួលខុសត្រូវចំពោះការទូទាត់ជូនធនាគារនូវរាល់ការចំណាយ កម្រៃ និងសោហ៊ុយដែលកើតមាន។ ធនាគាររក្សាសិទ្ធិកាត់ប្រាក់ពីចេញគណនីចរន្តសន្សំរបស់ម្ចាស់គណនី ឬគណនីប្រាក់បញ្ញើមានកាលកំណត់ eFD ចំពោះការចំណាយ កម្រៃ និងសោហ៊ុយ។

## ៨. ការព្យួរគណនីប្រាក់បញ្ញើមានកាលកំណត់ eFD

៨.១ ទំនាក់ទំនងជាប់កិច្ចសន្យារវាងម្ចាស់គណនី និងធនាគារនឹងត្រូវបានបញ្ចប់ ហើយប្រតិបត្តិការគណនីប្រាក់បញ្ញើមានកាលកំណត់ eFD នឹងត្រូវបានព្យួរក្នុងកាលៈទេសៈដូចខាងក្រោម៖

ក. មរណៈភាព វិកលចរិត ឬក្ស័យធនរបស់ម្ចាស់គណនី និង/ឬ

ខ. ការអនុវត្តវិធានការផ្លូវច្បាប់ ឬដីកាតុលាការសម្រេចឱ្យធនាគារឈ្នះក្តីលើម្ចាស់គណនី។

## ៩. សិទ្ធិកាត់កង

៩.១ ក្នុងពេលណាមួយក្នុងអំឡុងរយៈពេលប្រាំពីរ (៧) ថ្ងៃ មុនពេលជូនដំណឹងទៅម្ចាស់គណនី ធនាគារអាចកាត់កង ឬផ្ទេរប្រាក់ដែលនៅសល់ទៅគណនីប្រាក់បញ្ញើមានកាលកំណត់ eFD ដើម្បីទូទាត់បំណុល។

## ១០. គោលនយោបាយប្រឆាំងការស៊ីសំណូក និងប្រឆាំងអំពើពុករលួយ

១០.១ ធនាគារបានអនុវត្តគោលនយោបាយប្រឆាំងការស៊ីសំណូក និងប្រឆាំងអំពើពុករលួយរបស់ខ្លួនតាមវិធីសាស្ត្រ "មិនលើកលែង" ចំពោះទម្រង់នៃការស៊ីសំណូក និងអំពើពុករលួយក្នុងការធ្វើអាជីវកម្មរបស់ខ្លួន។ សម្រាប់ព័ត៌មានស្តីពីគោលនយោបាយប្រឆាំងការស៊ីសំណូក និងប្រឆាំងអំពើពុករលួយ អតិថិជនអាចចូលទៅកាន់គេហទំព័ររបស់ធនាគារ។ ធនាគាររក្សាសិទ្ធិបញ្ចប់ទំនាក់ទំនងជាប់កិច្ចសន្យាភ្លាមៗ ក្នុងករណីអតិថិជន ឬមន្ត្រីណាមួយ ឬភ្នាក់ងាររបស់ធនាគារមានជាប់ពាក់ព័ន្ធនឹងការស៊ីសំណូក ឬអំពើពុករលួយ។

## ១១. កម្មវិធីប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធើណិត/ប្រព័ន្ធធនាគារចល័ត

ម្ចាស់គណនីធានាសងសំណងជូនធនាគារ និងរក្សាផ្តល់សំណងពេញលេញជូនធនាគារគ្រប់ពេល ក្នុងករណីធនាគារបានអនុវត្ត ឬរ៉ាប់រងលើការប្តឹងទាមទារ និងការទាមទារ ចំណាត់ការ និងសំណុំរឿងបណ្តឹង ការខាតបង់ និងការចំណាយ ក្នុងនោះរួមមានការចំណាយលើផ្លូវច្បាប់ រវាងមេធាវី និងកូនក្តី បូករួមទាំងការទទួលខុសត្រូវផ្សេងទៀតពាក់ព័ន្ធនឹង ឬកើតឡើងដោយសារការផ្តល់សិទ្ធិអនុញ្ញាតរបស់ម្ចាស់គណនី។ ម្ចាស់គណនីយល់ព្រមថា ការទទួលខុសត្រូវរបស់ខ្លួនខ្ញុំគឺជាការទទួលខុសត្រូវដែលបន្តអនុវត្ត ហើយនៅមានប្រសិទ្ធភាព និងសុពលភាព រហូតដល់ការទទួលខុសត្រូវនោះត្រូវបានអនុវត្តពេញលេញតាមតម្រូវការរបស់ធនាគារ។

## ១២. ការជូនដំណឹង និងទំនាក់ទំនង

១២.១ ម្ចាស់គណនីត្រូវជូនដំណឹងមកធនាគារ ក្នុងករណីមានការផ្លាស់ប្តូរអាសយដ្ឋាន។ រាល់ទំនាក់ទំនងទាំងអស់ពីធនាគារ តាមអាសយដ្ឋាន ឬបញ្ជូនទៅម្ចាស់គណនីគឺចាត់ទុកថាបានបញ្ជូនត្រឹមត្រូវ ប្រសិនបើបញ្ជូននោះទៅអាសយដ្ឋានចុងក្រោយដែលបានផ្តល់ជូនធនាគារ។

១២.២ រាល់ការជូនដំណឹង និងទំនាក់ទំនងទៅកាន់ម្ចាស់គណនីនឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងអាចផ្ញើទៅម្ចាស់គណនីតាមអ៊ីម៉ែល ឬតាមរយៈការបិទផ្សាយនៅក្នុងបរិវេណធនាគារ និងនៅលើ

គេហទំព័ររបស់ធនាគារ។ រាល់ដំណើរការតាមផ្លូវច្បាប់នឹងត្រូវផ្ញើ និងទទួល ប្រសិនបើផ្ញើទៅម្ចាស់គណនី តាមរយៈប្រៃសណីយ៍ ឬផ្ញើទៅអាសយដ្ឋានចុងក្រោយដែលបានផ្តល់ជូនធនាគារ។

១២.៣ ធនាគារអាចនឹងកំណត់ ឬកែប្រែកម្រៃ និងសោហ៊ុយ ដែលបានអនុម័តដោយមិនមានការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ដោយបង្ហាញកម្រៃ និងសោហ៊ុយថ្មីនៅក្នុងបរិវេណធនាគារ និងនៅលើគេហទំព័ររបស់ធនាគារប៉ុណ្ណោះ។

## ១៣. ព័ត៌មានទូទៅ

១៣.១ ម្ចាស់គណនីប្រកាសថា មុនពេល ឬនៅពេលបើកគណនីប្រាក់បញ្ញើមានកាលកំណត់ eFD នេះ ម្ចាស់គណនីមិនត្រូវបាន៖

ក. រាយការណ៍ព័ត៌មានអំពីមូលប្បទានបត្រមិនមានទឹកប្រាក់គ្រប់គ្រាន់ ឬគ្មានទឹកប្រាក់ដោយធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល ១២ ខែចុងក្រោយ និង/ឬ

ខ. ធ្លាប់ប្រកាសក្ស័យធន និង/ឬ

គ. ធ្លាប់មានសេចក្ដីសម្រេច ឬញត្តិឱ្យរំលាយក្រុមហ៊ុន ឬអសោធនភាពមកលើម្ចាស់គណនី។

ធនាគារមានសិទ្ធិបិទគណនីប្រាក់បញ្ញើមានកាលកំណត់ eFD គ្រប់ពេល ដោយមិនមានការជូនដំណឹងជាមុន ក្នុងករណីម្ចាស់គណនីបំពានលក្ខខណ្ឌខាងលើ។

១៣.២ ធនាគាររក្សាសិទ្ធិក្នុងការផ្លាស់ប្ដូរ កែប្រែ ពិនិត្យឡើងវិញនូវខ និងលក្ខខណ្ឌណាមួយដែលមាននៅក្នុងខ និងលក្ខខណ្ឌនេះ លក្ខណៈពិសេស និងអត្ថប្រយោជន៍គណនី eFD តាមរយៈការបិទផ្សាយសេចក្ដីជូនដំណឹងអំពីការកែប្រែក្នុងបរិវេណធនាគារ និងគេហទំព័ររបស់ធនាគារ មុនពេលការកែប្រែមានប្រសិទ្ធិភាព។

១៣.៣ ក្នុងករណីអនុវត្តសម្រាប់គណនីចរន្តសន្សំដែលជាគណនីរួម ខ្ញុំ/យើងខ្ញុំដែលជាម្ចាស់គណនីយល់ព្រមថាក្នុងករណីម្ចាស់គណនីណាម្នាក់ទទួលមរណៈភាព ធនាគារមានសិទ្ធិទូទាត់សមតុល្យដែលសល់នៅក្នុងគណនីជូនម្ចាស់គណនីដែលនៅរស់ ហើយការទូទាត់នោះត្រូវចាត់ទុកថា ធនាគារបានអនុវត្តកាតព្វកិច្ចទូទាត់ប្រាក់នៅក្នុងគណនីនោះ។

**សម្គាល់៖** ប្រតិបត្តិការគណនីរួមគ្នា តម្រូវឱ្យចុះហត្ថលេខាលើប្រតិបត្តិការដោយម្ចាស់គណនីទាំងពីរ ឬនណារម្នាក់ក្នុងចំណោមម្ចាស់គណនីទាំងពីរ។

១៣.៤ តាមរយៈការទទួលយកខ និងលក្ខខណ្ឌទាំងនេះ ម្ចាស់គណនីយល់ព្រមថា ខ្ញុំ/យើងខ្ញុំបានអាន និងយល់ច្បាស់អំពី ខ និងលក្ខខណ្ឌរបស់កម្មវិធីប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធើណិត/ប្រព័ន្ធធនាគារចល័តរបស់ធនាគារ។ ម្ចាស់គណនីយល់ព្រមបន្ថែមទៀតថានឹងអនុវត្តតាម និងភ្ជាប់កាតព្វកិច្ចតាម ខ និងលក្ខខណ្ឌរួមទាំងការធ្វើ វិសោធនកម្ម ឬការកែប្រែ ខ និងលក្ខខណ្ឌទាំងនេះដែលធនាគារអាចនឹងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ដែលនឹងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ធនាគារ www.cpbebank.com.kh និង/ឬក្ដារខៀនជូនដំណឹងនៅតាមសាខា និង/ឬការផ្សព្វផ្សាយតាមមធ្យោបាយណាមួយផ្សេងទៀតដែលធនាគារបានអនុម័ត។

ម្ចាស់គណនីដែលបន្តរក្សា និងធ្វើប្រតិបត្តិការគណនី eFD ត្រូវបានចាត់ទុកថាបានយល់ព្រមទទួលការធ្វើវិសោធនកម្ម ឬកែប្រែខ និងលក្ខខណ្ឌរបស់កម្មវិធីប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធើណិត/ប្រព័ន្ធធនាគារចល័ត។

១៣.៥ បទប្បញ្ញត្តិដូចបានរៀបរាប់នៅក្នុងខ និងលក្ខខណ្ឌនេះ ធនាគាររក្សាសិទ្ធិមិនឱ្យធ្វើប្រតិបត្តិការគណនី eFD ប្រសិនបើធនាគារសង្ស័យថាគណនីខាងលើប្រើប្រាស់ក្នុងគោលបំណងខុសច្បាប់។

១៣.៦ ធនាគារអាចនឹងទទួលយក ឬច្រានចោលការស្នើសុំបើកគណនី eFD ដោយមិនផ្តល់ហេតុផល។